លោក សម រង្ស៊ី ប្រធានស្តីទីអតីតគណបក្សសង្គ្រោះជាតិ បានលើកឡើងថា វិបត្តិបំណុលធ្វើឲ្យប្រជាពលរដ្ឋខ្មែរខ្លះបានធ្វើអត្តឃាតខ្លួនឯង។ បញ្ហានេះលោក សម រង្ស៊ី ក៏បានចោទថា រដ្ឋាភិបាលក៏មានជាប់ពាក់ព័ន្ធដែរ។

ប៉ុន្តែអ្នកនាំពាក្យសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជាថា វិបត្តិបំណុលធ្វើឲ្យប្រជាពលរដ្ឋខ្មែរខ្លះបានធ្វើអត្តឃាតខ្លួនឯងនេះ មិនជាប់ពាក់ព័ន្ធនឹងសមាជិកខ្លួនដោយផ្ទាល់ឡើយ ករណីនេះអាចជាប់ពាក់ព័ន្ធបំណុលក្រៅប្រព័ន្ធច្រើនជាង។

ដោយដកស្រង់ចេញពីសារព័ត៌មានអង់គ្លេសដែលមានឈ្មោះថា The Guardian លោក សម រង្ស៊ី បាននិយាយថា

«មានពលរដ្ឋរាប់មិនអស់ទូទាំងប្រទេសជួបប្រទះវិបត្តិបំណុលយ៉ាងធ្ងន់ធ្ងរ ដីខ្លួនមិនរួចអស់សង្ឃឹម រហូតដល់ចង់សម្លាប់ខ្លួន ឬក៏ធ្វើអត្តឃាតរួចទៅហើយ»។ លោក សម រង្ស៊ី បានចោទរដ្ឋាភិបាលដឹកនាំដោយលោក ហ៊ុន សែននិងរដ្ឋាភិបាលថ្មីដឹកនាំដោយលោក ហ៊ុន ម៉ាណែត ជាអ្នកចូលដៃជាមួយធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុខិលខូចកេងប្រវ័ញ្ចពលរដ្ឋក្រីក្រ ដើម្បីទទួលបានប្រាក់ចំណេញ។

អត្ថបទសារព័ត៌មានអង់គ្លេស The Guardian

បានសរសេររៀបរាប់អំពីគ្រួសារក្រីក្រមួយនៅខេត្តរតនៈគិរី

ដែលស្វាមីបានស្លាប់ដោយសារតែបញ្ហាខ្ចីលុយធនាគារ

និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ពុំមានលទ្ធភាពសងត្រឡប់ទៅវិញ។

សារព័ត៌មាននេះបានស្រង់សម្ដីគ្រួសារជនរងគ្រោះ មុនឈានដល់ការសម្លាប់ខ្លួន

គឺបន្ទាប់ពីធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មករំលឹកដល់ផ្ទះដើម្បីដាស់

តឿនឲ្យជនរងគ្រោះសងប្រាក់ដែលបានជំពាក់។

តាមសារព័ត៌មានអង់គ្លេសដដែល

ប្រទេសកម្ពុជាតំណាងឲ្យវិស័យមីក្រូហិរញ្ញវត្ថុដ៏ធំបំផុតមួយរបស់ពិភពលោក

ជាមួយនឹងប្រាក់កម្ចីសរុបចំនួន 16 ពាន់លានដុល្លារ។ ដោយឡែក

ក្រុមហ៊ុនមីក្រូប្រាក់កម្ចីដ៏ធំបំផុតមួយចំនួននៅកម្ពុជា

កំពុងស្ថិតក្រោមការត្រួតពិនិត្យពីសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC)

របស់ក្រុមធនាគារពិភពលោកសម្រាប់ការខូចខាតដែលត្រូវ

បានចោទប្រកាន់ថាបណ្ដាលមកពីការផ្ដល់ប្រាក់កម្ចី រួមមាន "ការបាត់បង់ដីធ្លី

ផលប៉ះពាល់លើជីវភាពរស់នៅ ផលប៉ះពាល់លើជនជាតិដើមភាគតិច

និងការគំរាមកំហែងជាដើម"៕